# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការប្តេជ្ញាចិត្ត របស់គណបក្សនយោបាយ
# ក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មានសម្រាប់ទាំងអស់គ្នា

ភ្នំពេញ៖ ក្រុមការងារសិទ្ធិទទួលព័ត៌មាន ដែលហៅជាភាសាអង់គ្លេសថា Access to Information Working Group (A2IWG) បានបញ្ចប់ប្រកបដោយជោគជ័យនូវការរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី **"ព័ត៌មានសម្រាប់អ្នកទាំងអស់គ្នា"** ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា (រាជធានីភ្នំពេញ)។ សិក្ខាសាលានេះធ្វើឡើងក្រោមអធិបតីភាពរបស់ **ឯកឧត្តម មាស សុភ័ណ្ឌ អ្នកនាំពាក្យក្រសួងព័ត៌មាន** និងមានអ្នកចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ **សរុបចំនួន១០៧នាក់ (ស្រី៣៩នាក់)** ក្នុងនោះក៏មានការចូលរួមពីគណៈកម្មាការនៃរដ្ឋសភា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ជាតិ (គ.ជ.អ.ប) នឹងមានដៃគូអភិវឌ្ឍន៍ផ្សេងទៀតដូចជា៖ UNICEF UNDP SIDA OHCHR-UN GIZ Pact តំណាងអង្គការសង្គមស៊ីវិល តំណាងអាជ្ញាធរមូលដ្ឋាន អង្គការសហគមន៍មូលដ្ឋានមកពីខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងជនជាតិដើមភាគតិច។

គណបក្សនយោបាយចំនួនបួនបានចូលរួមផងដែរ៖

- **ឯកឧត្តម ខៀវ ណារី** អនុប្រធានគណៈកម្មាធិការឃោសនាបោះឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា
- **ឯកឧត្តម ញឿន រ៉ាដែន** អ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិច
- **លោក ទិព្វ ទាវ** អគ្គលេខាធិការរងគណបក្សខ្មែររួបរួមជាតិ
- **លោក យ៉េង វីរៈ** ប្រធានគណបក្សប្រជាធិបតេយ្យមូលដ្ឋាន

ជាលទ្ធផលគណបក្សនយោបាយទាំងបួន ដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សាបានប្តេជ្ញាចិត្តទៅកាន់អ្នកចូលរួមនៅក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន។ **ឯកឧត្តម ខៀវ ណារី អនុប្រធានគណៈកម្មាធិការឃោសនាបោះឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា**បានលើកឡើងថា នៅក្នុងផែនការទាំងអស់របស់គណបក្សប្រជាជនកម្ពុជា កំពុងយកចិត្តទុកដាក់លើច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ លោកបន្តថា អាណត្តិក្រោយ គណបក្សនេះនឹងបន្តជំរុញការអនុវត្តយុទ្ធសាស្ត្រ រួមទាំងលើសិទ្ធិទទួលព័ត៌មាន។ ឯកឧត្តមខៀវ ណារី បន្តទៀតថា ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន នៅតែជាអាទិភាពរបស់គណបក្សប្រជាជនកម្ពុជា ដែលគាំទ្រជំរុញឱ្យមានការអនុម័តច្បាប់នេះឱ្យបានឆាប់។ ឯកឧត្តមបន្តដែរថា ការប្តេជ្ញាចិត្តជាលាយលក្ខណ៍អក្សរគាំទ្រច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដើម្បីជួយប្រជាពលរដ្ឋក្នុងការរស់នៅ និងធ្វើការ។ **លោក យ៉េង វីរៈ ប្រធានគណបក្សប្រជាធិបតេយ្យមូលដ្ឋាន** មានប្រសាសន៍ថា គណបក្សនេះនឹងជំរុញឱ្យពន្លឿនសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ លោកក៏គាំទ្រ និងជំរុញឱ្យដាក់ធាតុចូលរបស់ក្រុមអង្គការសង្គមស៊ីវិល នៅក្នុងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានផងដែរ។ លោកបញ្ជាក់ថា គណបក្សរបស់លោក នឹងគាំទ្រលើសិទ្ធិទទួលព័ត៌មាន ប្រសិនមានអាសនៈក្នុងរដ្ឋសភានាពេល

អនាគត។ **ឯកឧត្តម ញឿន រ៉ាដែន អ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិច** មានប្រសាសន៍ថា គណបក្សនេះគាំទ្រយ៉ាងពេញទំហឹង និងប្តេជ្ញាចូលរួម អនុវត្តគាំទ្រ ដល់ច្បាប់ទទួលព័ត៌ មាន។ លោកក៏គាំទ្រឱ្យមានការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ឱ្យបានឆាប់តាមដែលអាចធ្វើបាន ដោយលោកលើកហេតុផលថា ច្បាប់នេះមានសារៈសំខាន់ណាស់ ក្នុងការជួយប្រជាពលរដ្ឋក្នុងការប្រកបមុខរបរ។ **លោក ទិត្យ ទាវ អគ្គលេខាធិការរងគណបក្សខ្មែររួបរួមជាតិ** គាំទ្រទាំងស្រុងលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ក៏មានចក្ខុវិស័យក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាផងដែរ។ លោកលើកឡើងថាការអនុវត្តបច្ចេកវិទ្យាគឺល្អសម្រាប់ការអភិវឌ្ឍវាត្រូវការ ការចូលរួមពីប្រជាជន។ លោកបង្ហាញសុទិដ្ឋិនិយមថា ច្បាប់នេះនឹងអាចសម្រេចបានពិតប្រាកដក្នុងរដ្ឋាភិបាលអាណត្តិក្រោយ។

នៅចុងបញ្ចប់នៃកិច្ចពិភាក្សា នៅក្នុងសិក្ខាសាលា គណបក្សនយោបាយទាំងអស់បានប្រកាស់គាំទ្រទាំងស្រុងក្នុងការជំរុញឱ្យច្បាប់ស្តីពីសិទ្ធិទទួលព័ត៌ មានអនុម័តអោយបានឆាប់ៗ ដើម្បីជំរុញការបើកចំហព័ត៌មាន និងតម្លាភាព ជាពិសេសការផ្តល់ព័ត៌មាន ស្តីពីថវិកាដល់ប្រជាពលរដ្ឋអោយបានទូលាយ។ បើតាមតំណាងគណបក្សនយោបាយ ដែលបានចូលរួមបានបង្ហាញសុទិដ្ឋិនិយមដែរថា ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ក៏នឹងជំរុញមានការយកចិត្តទុកដាក់បន្ថែមទៀត លើការយល់ដឹងដល់ថ្នាក់ក្រោមជាតិ ជាពិសេសគោលនយោបាយផ្ទេរការយល់ដឹងពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិស្តីពីសិទ្ធិទទួលព័ត៌មាន។ ពួកគាត់ក៏ទទូចឱ្យរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចូលរួមគ្រប់គ្នាក្នុងការជំរុញ ផ្សព្វផ្សាយអំពីសិទ្ធិទទួលព័ត៌មាន និងព័ត៌មានថវិកា ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមទាំងអស់គ្នា និងបង្ហាញពីការប្តេជ្ញាចិត្ត ក្នុងការបន្តធ្វើការរួមគ្នាក្នុងភាពជាដៃគូប្រកបដោយវិជ្ជាជីវៈ និងលើកកម្ពស់សុខុមាលភាពសង្គម៕

**បញ្ជីឈ្មោះស្ថាប័នចូលរួមសហការ និងរៀបចំដោយៈ**

១. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
២. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
៣. អង្គការតម្លាភាពកម្ពុជា (TIC)
៤. អង្គការទិន្នន័យដើម្បីការអភិវឌ្ឍន៍ (ODC)
៥. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
៦. មជ្ឈមណ្ឌលសិទ្ធមនុស្សកម្ពុជា (CCHR)
៧. វេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOForum)
៨. សមាគមន៍សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJa)
៩. គណៈម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
១០. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
១១. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
១២. អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)
១៣. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ (CCIM)


**<u>ព័ត៌មានបន្ថែមសូមទាក់ទងៈ</u>**

ឈ្មោះ ៖ លោក **ឡោ គីមស្រ៊ូវ** មន្ត្រីកម្មវិធី
លេខទូរសព្ទ ៖ +៨៥៥ (0) ០៨១ ៨២ ៨៣ ៩១/ ០៨៨ ៧៧ ១១ ០៧៧
អាសយដ្ឋានអ៊ីមែល ៖ kimsrauv.lor@cpddcambodia.org